# មេរៀនទី ១៣០: ប៉ុលបង្រៀននៅក្រុងអាថែន

## កិច្ចការ ១៧:១៦-៣១

**គោលបំណង៖** ព្រះមានព្រះជន្មរស់។

**ខគម្ពីរចងចាំ៖ ម៉ាថាយ ១៦:១៦** *"ស៊ីម៉ូន-ពេត្រុសទូលឆ្លើយថា ទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ចំណងមិត្តភាពជាមួយព្រះយេស៊ូវគឺអស្ចារ្យណាស់ ដល់ថ្នាក់មិត្តភក្តិរបស់ព្រះយេស៊ូវមានឆន្ទៈក្នុងការប្រថុយជីវិត ដើម្បីអញ្ជើញអ្នកដទៃឱ្យចូលរួមក្នុងមិត្តភាពនោះ។ សូមអាន **កិច្ចការ ១៧:១៦-៣១**។ រង់ចាំមើលថាតើក្រុមមនុស្សនីមួយៗមានភាពខុសប្លែកពីលោកប៉ុលយ៉ាងដូចម្តេច។ ហេតុអ្វីបានជាគាត់អាចស្រឡាញ់មនុស្សដែលមានជំនឿខុសៗគ្នា ជាជាងវិនិច្ឆ័យគេថាអាក្រក់ ឬមិនល្អ? ក្នុងជីវិតរបស់អ្នក តើនរណាមានជំនឿផ្សេងៗពីអ្នក? តើអ្នកអាចបង្ហាញសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវ ចំពោះបុគ្គលនោះដូចជាប៉ុលបានបង្ហាញសេចក្តីស្រឡាញ់ចំពោះក្រុងអាថែនយ៉ាងដូចម្តេច?

**ចំរៀង៖** ១. ខ្ញុំចង់ស្គាល់ព្រះគ្រីស្ទ ២. ខ្ញុំដើរតាមព្រះយេស៊ូវ ៣. ខ្ញុំដឹងថា

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត** «បាញ់»



១. ឲ្យកុមារអង្គុយជារង្វង់។

២. គ្រូត្រូវឈរនៅកណ្តាលរង្វង់ ហើយចង្អុលទៅកុមារណាម្នាក់។

៣. ហើយកុមារត្រូវតែអោនចុះ ហើយកុមារដែលនៅសងខាងកុមារនោះ ខាងស្តាំ និងខាងឆ្វេងត្រូវបាញ់គ្នាទៅវិញទៅមក។ កុមារណាដែលអាចបាញ់ទៅគេបានមុនគឺអាចលេងបន្តបាន ហើយកុមារណាដែលបាញ់ក្រោយនឹងចាញ់ល្បែងនេះ។

៤. បន្តលេងល្បែងនេះរហូតដល់កុមារគ្រប់គ្នាបានលេងគ្រប់ៗគ្នា។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ពួកយើងគឺត្រូវតែប្រុងប្រៀបជានិច្ចក្នុងការចែកចាយអំពីដំណឹងល្អ។

## ៤. ការណែនាំមេរៀន

វាជាដំណឹងល្អដែលព្រះយេស៊ូវបានប្រសូត សោយទិវង្គតនៅលើឈើឆ្កាង ទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយនឹងយាងមកម្តងទៀតក្នុងពេលឆាប់ៗនេះ។ វាជាដំណឹងល្អព្រោះវាជាការពិត! វាជាដំណឹងល្អ ពីព្រោះព្រះមានព្រះជន្មរស់ ហើយវាជាការពិត។ ប៉ុន្តែមនុស្សខ្លះគិតថាព្រះមិនមែនព្រះពិតទេ។ ពេលសាវកប៉ុលបានទៅដល់កន្លែងមួយឈ្មោះអាថែន មនុស្សនៅទីនោះមិនជឿលើព្រះទេ។ ចូរយើងស្វែងយល់ពីរបៀបដែលប៉ុលអាចចែកចាយដំណឹងល្អរបស់ព្រះយេស៊ូវដល់ពួកគេ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅសម័យព្រះគម្ពីរ ក្រុងអាថែនគឺជាទីក្រុងដ៏ល្បីល្បាញរបស់ក្រិច។ សាវកប៉ុលបានទៅក្រុងអាថែន ដើម្បីប្រាប់ប្រជាជនអំពីព្រះយេស៊ូវ។ គាត់បានរកឃើញអ្វីមួយដែលធ្វើឱ្យគាត់សោកសៅ។ ប្រជាជននៅទីក្រុងអាថែនបានសាងសង់របស់ដែលធ្វើពីថ្ម ឈើ និងលោហៈ ហើយពួកគេកំពុងថ្វាយបង្គំនូវអ្វីដែលពួកគេបានសាងសង់នោះ! ទាំងនេះត្រូវបានគេហៅថារូបព្រះ។ រូបព្រះ គឺជាអ្វីដែលមនុស្សស្រឡាញ់ច្រើនជាងព្រះដ៏មានព្រះជន្មរស់។ គេគិតថារូបព្រះដែលគេបង្កើតគឺជាព្រះ!

មនុស្សថ្វាយបង្គំរូបព្រះសូម្បីតែព្រះដែលគេមិនស្គាល់ ព្រះគម្ពីរចែងថា៖ “ចំពោះព្រះដែលមិនស្គាល់។” នៅពេលដែលប៉ុលបានឃើញរូបព្រះជាព្រះដែលមិនស្គាល់ គាត់ដឹងថាគាត់គួរតែប្រាប់ប្រជាជនអាថែន អំពីព្រះដ៏មានព្រះជន្មរស់។

ប៉ុលបានប្រាប់មនុស្សថា ព្រះបានបង្កើតលោកីយ៍ និងអ្វីៗទាំងអស់នៅលើផែនដីនេះ។ គាត់បានពន្យល់ថាព្រះបានបញ្ជូនព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវមកសុគតនៅលើឈើឆ្កាងសម្រាប់អំពើបាបរបស់យើង។ ប៉ុលបានពន្យល់ថា ព្រះបានបង្ហាញថាទ្រង់ជាព្រះនៅពេលដែលព្រះអង្គបានប្រោសព្រះយេស៊ូវពីសុគតឡើងវិញ។ ព្រះនៅមានព្រះជន្មរស់! ប៉ុលបានពន្យល់ថា ព្រះមិនដូចជាប្រាក់ ឬមាស ឬថ្ម មិនមែនជារូបដែលបង្កើតឡើងដោយការរចនា និងជំនាញរបស់មនុស្សឡើយ។ ប៉ុលបានប្រាប់ប្រជាជនក្រុងអាថែនថាពួកគេត្រូវការប្រែចិត្ត ហើយជឿលើព្រះដ៏មានព្រះជន្មរស់ពិត។ មនុស្សជាច្រើនបានស្តាប់ប៉ុល ហើយបានក្លាយជាគ្រីស្ទាន។ ប៉ុន្តែនោះមានន័យថាពួកគេត្រូវបំផ្លាញរូបព្រះរបស់ពួកគេចោល។ អ្នកខ្លះសប្បាយចិត្តនឹងធ្វើវា ខ្លះទៀតមិនសប្បាយចិត្តទេ។ ប៉ុន្តែព្រះទ្រង់មានព្រះជន្មរស់ ហើយទ្រង់ប្រសើរជាងអ្វីៗ ដែលគេបានបង្កើតមកជាទីគោរពប្រណិប័តន៍ទៅទៀត។

ពេលខ្លះ យើងអាចមានរូបព្រះក្នុងជីវិតរបស់យើង ដោយការស្រឡាញ់អ្វីមួយច្រើនជាងព្រះ។ វាអាចជាលុយឬភាពលោភលន់ ឬភាពអាត្មានិយម។ យើងត្រូវតែចាំថាព្រះជាម្ចាស់ប្រសើរជាងអ្វីៗទាំងអស់ ដែលពិភពលោកនេះអាចផ្តល់ឱ្យបាន ពីព្រោះព្រះរបស់យើងមានព្រះជន្មរស់! ការមានព្រះជន្មរស់ឡើងវិញ របស់ព្រះយេស៊ូវបានបញ្ជាក់ថាព្រះអង្គនៅមានជីវិត។

មនុស្សមួយចំនួនមិនជឿថាព្រះយេស៊ូវពិតជាបានរស់ឡើងវិញទេ។ មនុស្សខ្លះដែលរស់នៅពេលព្រះយេស៊ូវគង់នៅផែនដីនៅឡើយបានគិតថា មិត្តរបស់ព្រះអង្គបានលួចយកសពព្រះអង្គទៅ។ ប៉ុន្តែព្រះយេស៊ូវបានបង្ហាញខ្លួន

ដល់ពួកសិស្សរបស់ព្រះអង្គបានឃើញជាច្រើនដង បន្ទាប់ពីព្រះអង្គបានរស់ពីសុគតឡើងវិញ។ ការបង្ហាញខ្លួនទាំងនោះបញ្ជាក់ថាព្រះយេស៊ូវបានរស់ឡើងវិញ។ ពួកសិស្សរបស់ព្រះយេស៊ូវសុខចិត្តរងទុក្ខ ដើម្បីចែកចាយដំណឹងល្អអំពីព្រះដែលទ្រង់មានព្រះជន្មរស់ ដោយសារពួកគេបានឃើញព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ។

តើអ្នកជឿថាព្រះនៅមានព្រះជន្មរស់ឬទេ? តើអ្នកជឿថាព្រះប្រសើរជាងរូបព្រះណាមួយក្នុងលោកនេះទេ? សូមឲ្យយើងធ្វើដូចលោកប៉ុលក្នុងព្រះគម្ពីរថ្ងៃនេះ ហើយប្រាប់អ្នកឯទៀតថាព្រះមានព្រះជន្មរស់!

## ៦. សំនួរពិភាក្សា

១. តើប៉ុលបានទៅទីក្រុងណានៅក្នុងរឿងគម្ពីរនេះ? *ក្រុងអាថែន*

២. តើក្រុងអាថែនចូលចិត្តថ្វាយបង្គំអ្វី? *រូបព្រះ*

៣. តើរូបព្រះជាអ្វី? *អ្វីៗដែលមនុស្សថ្វាយបង្គំ និងស្រឡាញ់ច្រើនជាងព្រះ*

៤. តើប៉ុលព្យាយាមប្រាប់មនុស្សឱ្យជឿលើព្រះដោយរបៀបណា?
*គាត់បានពន្យល់អំពីការរស់ឡើងវិញរបស់ព្រះយេស៊ូវ ដែលបង្ហាញថាព្រះមានព្រះជន្មរស់ឡើងវិញ*

៥. តើយើងដឹងយ៉ាងណាថាព្រះមានព្រះជន្មរស់? *ដោយសារព្រះយេស៊ូវបានសុគត ហើយបានប្រោសឲ្យរស់ឡើងវិញ ហើយមនុស្សជាច្រើនបានឃើញព្រះយេស៊ូវដែលមានព្រះជន្មរស់ឡើងវិញ ដោយសារ ព្រះនៅតែធ្វើការក្នុងជីវិតរបស់យើងដោយធ្វើល្អចំពោះយើង*

៦. តើអ្នកអាចប្រាប់អ្វីខ្លះដល់មិត្តភក្តិដែលមិនទាន់ជឿលើព្រះដើម្បីបង្ហាញថាព្រះមានជីវិតរស់នៅ?
*ឱ្យកុមារឆ្លើយ*

## ៧. ល្បែងកំសាន្ត «បោះកំពស់»

**សម្ភារៈដែលត្រូវការ៖** បាល់មួយ




១. ឲ្យកុមារឈរជារង្វង់

២. គ្រូឈរនៅកណ្តាលរង្វង់ហើយដាក់លេខរៀងឲ្យកុមារគ្រប់ៗគ្នា

៣. គ្រូនិងបោះបាល់ទៅលើនិងនិយាយលេខណាមួយក្នុងពេលតែមួយ

៤. កុមារដែលលឺលេខរបស់ខ្លួនត្រូវរត់ទៅចាប់បាល់ដែលគ្រូបោះនោះ។ ប្រសិនគេមិនអាចចាប់បាល់បានទេនោះគេនឹងចាញ់ល្បែងនេះ ហើយមិនអាចបន្តលេងល្បែងនេះបានទេ។




៥. បន្តលេងល្បែងនេះរហូតដល់កុមារគ្រប់គ្នាចាញ់ទាំងអស់។

៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ពួកយើងនឹងស្លាប់នៅថ្ងៃណាមួយ។ ប៉ុន្តែព្រះមិនដែលសុគតនោះទេ ហើយទ្រង់នឹងផ្តល់ជីវិតអស់កល្បដល់យើងនៅឯនគរស្ថានសួគ៌។ ដូច្នេះយើងគួរតែចែកចាយពីដំណឹងល្អនៃជីវិតអស់កល្បនៅក្នុងព្រះជាមួយអ្នកដទៃដែរ។

## ៨. ខគម្ពីរចងចាំ ម៉ាថាយ ១៦:១៦

## ៩. ហត្ថកម្ម «ព្រះមានព្រះជន្មរស់!»




**សម្ភារៈដែលត្រូវការៈ** បោះពុម្ពសន្លឹកហត្ថកម្ម កូល័រទៀន កន្ត្រៃ និងកាវបិត

១. ឲ្យសន្លឹកហត្ថកម្មទៅកុមារម្នាក់១សន្លឹក។

២. ឱ្យកុមារផាត់ពណ៌លើរូបភាពនៅខាងក្រៅឈើឆ្កាង។

៣. ពន្យល់ដល់កុមារថា ព្រះមានព្រះជន្មរស់ ដោយសារទ្រង់ជាអ្នកបង្កើតអ្វីៗទាំងអស់នៅក្នុងពិភពលោកនេះ។ បន្ទាប់មក ឲ្យកុមារកាត់រូបភាពផែនដីកាត់រួចហើយយកកាវបិតនៅលើឈើឆ្កាង។

៤. សូមពន្យល់ដល់កុមារថា ព្រះមានព្រះជន្មរស់ ដោយសារទ្រង់បានមកឯយើងជាទារក។ បន្ទាប់មក ឱ្យកុមារផាត់ពណ៌រូបព្រះអង្គប្រសូត្រ បន្ទាប់ពីកាត់ហើយយកការមកបិតនៅផ្នែកខាងឆ្វេងនៃឈើឆ្កាង។

៥. ពន្យល់ដល់កុមារថា ព្រះមានព្រះជន្មរស់ ដោយសារព្រះយេស៊ូវបានសុគតជំនួសអំពើបាបរបស់យើង។ បន្ទាប់មកឱ្យកុមារផាត់ពណ៌រូបព្រះលីឈើឆ្កាង បន្ទាប់ពីកាត់ហើយយកការមកបិតនៅផ្នែកខាងស្តាំនៃឈើឆ្កាង។

៦. សូមពន្យល់កុមារថា ព្រះមានព្រះជន្មរស់ ដោយសារព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញ។ បន្ទាប់មកឲ្យកុមារផាត់ពណ៌ផ្នូរទទេ និងព្រះយេស៊ូវ បន្ទាប់ពីកាត់ហើយយកការមកបិតនៅផ្នែកខាងក្រោមនៃឈើឆ្កាង។

៧. ពន្យល់ដល់កុមារថា ព្រះមានព្រះជន្មរស់ ដោយសារទ្រង់ស្រឡាញ់ និងយកចិត្តទុកដាក់ចំពោះយើងសូម្បីតែសព្វថ្ងៃនេះ! រួចឲ្យកុមារផាត់ពណ៌រូបព្រះយេស៊ូវជាមួយនឹងក្មេងៗ បន្ទាប់ពីកាត់ហើយយកការមកបិតជាប់នឹងផ្នែកខាងក្រោមគេនៃឈើឆ្កាង។

៨. កាត់ឈើឆ្កាងធំចេញ ហើយនិយាយថា "ព្រះមានព្រះជន្មរស់!"

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ព្រះមានព្រះជន្មរស់!





ព្រះ

មានព្រះ

ជន្មរស់!









